ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ៦៣/២០២៥ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

## លទ្ធផលនៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣
## រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
## និងក្រសួងការបរទេសនៃសាធារណរដ្ឋប៉ូឡូញ

រដ្ឋធានីវ៉ាសូវី ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥៖ **លោកជំទាវ ជ្រឹង បុទុមរង្សី** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម វ៉ាឌីស្វាហ្វ បារតូចែហ្វស្គី** (Władysław T. Bartoszewski) រដ្ឋលេខាធិការនៃក្រសួងការបរទេសនៃសាធារណរដ្ឋប៉ូឡូញ បានធ្វើជាសហប្រធាននៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣រវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ។

សហប្រធានទាំងពីរបានស្វាគមន៍ចំពោះចំណងមិត្តភាពដ៏យូរអង្វែង និងកិច្ចសហប្រតិបត្តិការដ៏មានផ្លែផ្កាលើវិស័យដែលជាប្រយោជន៍ទៅវិញទៅមកជិតប្រាំពីរទសវត្សរ៍ ជាពិសេស ការរីកចម្រើនគួរជាពេញចិត្តលើវិស័យពាណិជ្ជកម្ម និងទំនាក់ទំនងប្រជាជននិងប្រជាជន។ រដ្ឋលេខាធិការទាំងពីរបានកត់សម្គាល់ដោយសេចក្ដីសោមនស្សរីករាយចំពោះការបន្តពង្រឹងទំនាក់ទំនងទ្វេភាគី ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈការរៀបចំជាទៀងទាត់នៃកិច្ចពិគ្រោះយោបល់ទ្វេភាគី វត្តមានរបស់ស្ថានកុងស៊ុលកិត្តិយសប៉ូឡូញនៅរាជធានីភ្នំពេញ និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីការលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត។ រដ្ឋលេខាធិការទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចសន្ទនាប្រកបដោយចីរភាព ដែលជាយន្តការដ៏សំខាន់មួយសម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែទូលំទូលាយរវាងកម្ពុជានិងប៉ូឡូញ។ លោកជំទាវរដ្ឋលេខាធិការបានសម្ដែងការកោតសរសើរយ៉ាងស្មោះស្ម័គ្ររបស់រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា ចំពោះការចូលរួមចំណែករបស់ប៉ូឡូញ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា។

ភាគីទាំងពីរបានបញ្ជាក់សាជាថ្មីនូវការតាំងចិត្តយ៉ាងមុតមាំក្នុងការជំរុញទំនាក់ទំនងទ្វេភាគីបន្ថែមទៀត ដោយបានពិភាក្សាគ្នាស៊ីជម្រៅលើប្រធានបទជាច្រើន រួមមានកិច្ចសហប្រតិបត្តិការនយោបាយ និងសេដ្ឋកិច្ច ជំនួយអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការដែលមានសក្ដានុពល ដូចជា ពាណិជ្ជកម្ម និងវិនិយោគ

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

សុខាភិបាល ទេសចរណ៍ អប់រំ កសិកម្ម និងកសិឧស្សាហកម្ម វប្បធម៌ ឌីជីថលនីយកម្ម ទំនាក់ទំនងរវាងប្រជាជននិងប្រជាជន និងកិច្ចសហប្រតិបត្តិការរវាងសភានៃប្រទេសទាំងពីរ។ ទន្ទឹមនឹងការទទួលស្គាល់ពីការរីកចម្រើនខ្លាំងក្នុងវិស័យពាណិជ្ជកម្ម ភាគីទាំងពីរបានកត់សម្គាល់នូវសក្តានុពលដែលនៅមាន និងបានឯកភាពស្វែងរកវិធីសាស្ត្រជាក់ស្តែងនានា ដើម្បីជំរុញការចូលរួមបន្ថែមទៀតក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តាមរយៈការរៀបចំកម្មវិធីដំណើរទេស្សនកិច្ចពាណិជ្ជកម្ម និងវិនិយោគ ទាំងនៅក្នុងប្រទេសកម្ពុជានិងក្នុងប្រទេសប៉ូឡូញ នាពេលខាងមុខ។ ភាគីទាំងពីរក៏បានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ រួមមាន អាស៊ាន សហភាពអឺរ៉ុប និងអង្គការសហប្រជាជាតិ។ ក្នុងន័យនេះ ភាគីទាំងពីរបានកត់សម្គាល់ដោយពេញចិត្តកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ តាមរយៈការផ្លាស់ប្តូរការគាំទ្របេក្ខភាពគ្នាទៅវិញទៅមក។

សហប្រធានទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាតំបន់ និងអន្តរជាតិសំខាន់ៗ ដែលជាក្តីកង្វល់រួម និងបានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់សន្តិភាព និងស្ថិរភាព នៅក្នុងតំបន់និងអន្តរជាតិ តាមរយៈកិច្ចសន្ទនាបែបស្ថាបនា និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ។ ក្នុងកិច្ចពិភាក្សានោះ លោកជំទាវរដ្ឋលេខាធិការក៏បានជម្រាបជូនអំពីការវិវត្តនៃស្ថានការណ៍ចុងក្រោយនៃបញ្ហាព្រំដែនកម្ពុជា-ថៃ។ **ឯកឧត្តម វ៉ាឌីស្វាហ្វ បារតូឆែហ្វស្គី** បានគូសបញ្ជាក់ពីសារៈសំខាន់នៃការដោះស្រាយដោយសន្តិវិធីចំពោះបញ្ហាព្រំដែន តាមរយៈការប្រើប្រាស់មធ្យោបាយ សន្តិវិធីស្របតាមច្បាប់អន្តរជាតិ និងការរៀបចំទ្វេភាគី និងបានជំរុញភាគីទាំងពីរបន្តស្វែងរកសន្តិភាព និងសុខដុមរមនាយូរអង្វែង។

កិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីនេះ បានប្រព្រឹត្តទៅប្រកបដោយបរិយាកាសកក់ក្តៅ និងស្និទ្ធស្នាល ហើយសហប្រធានទាំងពីរបានបញ្ជាក់ពីការត្រៀមខ្លួនរួចរាល់ក្នុងការរៀបចំកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីជុំបន្ទាប់ នៅកម្ពុជា តាមកាលបរិច្ឆេទសមស្រប។

ថ្ងៃ សុក្រ ៦កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ខែវិច្ឆិកា ឆ្នាំ២០២៥